គម្រោងការអភិវឌ្ឍន៍វិស័យកសិកម្ម

Agriculture Sector Development Project (ASDP)

# ក្រដែលលេខ ១០

## ស្តីពី

# ខួងស៊ីបំផ្លាញដូង និង វិធានការការពារ



រៀបចំដោយៈ ការិយាល័យផ្សព្វផ្សាយកសិកម្មខេត្តកំពត

ក្រោមឥណទាន ADB លេខ 2023-CAM [SF]

# ផលប្រយោជន៍នៃរុក្ខជាតិដូង

ម.ព.ឯ.ក AIDOC
Code: 177-005
Date:
Donated by:

☞ **ស្លឹកដូង:**

- ដេរប្រក់ផ្ទះ
- វេចនំ
- គ្រឿងតុបតែងលំអ
- កន្ទះដូង ធ្វើកន្ត្រក ធ្វើទ្រូ ឈើចាក់ធ្មេញ

☞ **ធាងដូង:**

- ធ្វើកន្ត្រក
- ធ្វើរបង
- ធ្វើទ្រុងជីកំប៉ុស្តិ
- អុសដុត

☞ **ដើមដូង:**

- ជាម្ហូប
- ការពារមិនអោយហូរច្រោះដី
- ធ្វើផ្ទះ
- វែក ស្លាបព្រា
- រូបចំលាក់
- ធ្វើស្ពាន

☞ **ផ្លែដូង:**

- ផ្លែខ្ចី ហូបទឹក និងសាច់ និង ធ្វើថ្នាំ
- ផ្លែខ្ចីកែច្នៃធ្វើទឹកដូងកំប៉ុង
- ផ្លែទុំ ធ្វើនំ
- ចំរាញ់ប្រេង ធ្វើសាប៊ូ
- ត្រឡោកដូង ធ្វើផ្តិលផឹកទឹក ធ្វើឧបករណ៍ភ្លេង
- ស្រកីដូង វិញខ្សែ ធ្វើអំបោស ធ្វើជីកំប៉ុស្តិ

# ការបំផ្លាញដូងដោយពពួកខ្ទួង

☞ ចាប់តាំងពីឆ្នាំ ២០០០ មក យើងសង្កេតឃើញមានការស៊ីបំផ្លាញរបស់ដង្កូវខ្ទួងដូងដែល មាន សណ្ឋាន ដូចជា ស៊ីបណ្ដូលដូង ខ្លោចស្លឹកដូង រលួយស្លឹកដូង និង ធ្វើអោយកំបុតកំពូលដូង ជាដើម ។ ខ្ទួងតែងតែស៊ីកំពូលស្លឹកដែលមិនទាន់រលាចេញ ដោយបង្កអោយស្លឹកទាំងនោះក្លាយ ជាក្រៀមស្ងួត ។

☞ ករណីដែលមានការរាតត្បាតខ្លាំងបណ្ដាលអោយ ទិន្នផលថយចុះ បន្ថយលទ្ធភាពក្នុងការ ចេញផ្កា ផ្លែ រួចងាប់តែម្ដង ។



ទិដ្ឋភាពនៃការបំផ្លាញដូង

**ការបំផ្លាញទាំងនេះបានធ្វើអោយខូចខាតយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិ និង ប្រាក់ចំណូល របស់កសិករយើង ។**

# អ្វីជាខ្មុងស៊ីបំផ្លាញដូង ?








### វដ្តជីវិតរបស់ខ្មុងមាន៤ដំណាក់កាល

| | | |
|---|---|---|
| ១- ពង | ☞ | ៥ ថ្ងៃ |
| ២- ដង្កូវ | ☞ | ៣០ ថ្ងៃ |
| ៣- ដឹកឌឿ | ☞ | ៧ ថ្ងៃ |
| ៤- ខ្មុងពេញវ័យរស់បានពី | ☞ | ១៨០-២២០ថ្ងៃ |

☞ មេខ្មុង ១ ក្បាល អាចពងបានចំនួន ២ទៅ ៥ ពងក្នុងមួយថ្ងៃ

☞ មួយវដ្តជីវិតវាអាចពងបាន ពី ១៥០-៤០០ ពង អាស្រ័យទៅលើចំណីអាហារ ។

☞ មេខ្មុងពេញវ័យ និង ដង្កូវ ស៊ីស្លឹកខ្ចីរបស់ដូង ដូងប្រេង ស្លា ចាក និង ស្លឹកពពួអំបូរ Cycas ជាអាហារ

# វិធានការការពារ

មានវិធីច្រើនយ៉ាងក្នុងការការពារ និង ដោះស្រាយបញ្ហាទាំងនោះដូចជាៈ

☞ ការប្រើថ្នាំពុលគីមី

☞វិធានការមេកានិច

☞វិធានការជីវសាស្ត្រ( ការប្រើប្រាស់ពពួកឱម៉ាល់អាសេកូដកំចាត់ខ្ទុងស៊ីដូង)

**ការប្រើប្រាស់ពពួកឱម៉ាល់អាសេកូដកំចាត់ខ្ទុងស៊ីដូង គឺ ជាវិធានការដែលមាន ប្រសិទ្ធភាពខ្ពស់ សន្សំសំចៃថវិកា និង មិនប៉ះពាល់ដល់បរិស្ថាន និង សុខភាព។**

## អ្វីជាឱម៉ាល់អាសេកូដកំចាត់ខ្ទុងស៊ីដូង?



Asecodes hispinarum



☞ ឱម៉ាល់មានពណ៌ខ្មៅ ប្រវែង១មីលីម៉ែត្រ ដែលមានឈ្មោះ អាសេកូដ ហ៊ីសពីណារូម

☞ មានប្រភពពីកោះសាម៉ាវខាងលិចនៃប្រទេសឥណ្ឌូណេស៊ី (Western Samoa)

☞ មេឱម៉ាល់១ក្បាល មានលទ្ធភាពពងបានពី ៣០ទៅ ១៦០ពង

☞ វដ្ដជីវិតរបស់ឱម៉ាល់មានៈ

១-ដំណាក់កាលដែលត្រូវផ្ញើខ្លួនក្នុងដង្កូវខ្ទុង ១៦ ទៅ ១៨ថ្ងៃ ចំពោះបរិស្ថានដែលមានសីតុណ្ហភាពសមស្រប ២៨ អង្សាសេ

២-ឱម៉ាល់ពេញវ័យអាចរស់ពី ៣ទៅ ៥ថ្ងៃ

# ឱម៉ាល់អាសេកូដមានប្រយោជន៍យ៉ាងដូចម្ដេចចំពោះកសិករ?

☞ សំលាប់ដង្កូវខ្ទុងស៊ីដូង

☞ សំលាប់ដង្កូវខ្ទុងស៊ីដូងប្រេង

☞ សំលាប់ដង្កូវខ្ទុងស៊ីស្លា

☞ សំលាប់ដង្កូវខ្ទុងស៊ីស្លឹកចាក

☞ សំលាប់ដង្កូវខ្ទុងស៊ីពពួកអំបូរ Cycas

# ការរស់នៅរបស់ឱម៉ាល់អាសេកូដ

☞ មានលទ្ធភាពប៉ារ៉ាស៊ីតលើដង្កូវខ្ទុងដូង ចាប់ដំណាក់ទី១ដល់ដំណាក់កាលទី ៤

☞ វាចូលចិត្តផ្ញើខ្លួនលើដង្កូវខ្ទុងដូងនៅដំណាក់កាលទី៤

☞ ឱម៉ាលអាសេកូដមានទំហំតូច និង មានសកម្មភាពយ៉ាងរហ័សណាស់

☞ វាមិនវាយប្រហារ ឬ បង្ករផលពាស់ពាល់ដល់មនុស្ស

☞ វាប្រើខ្ទុងដូងជាប្រភេទចំណីអាហារ

☞ វាចាក់បញ្ចូល ( ទិច) ពងទៅក្នុងដង្កូវខ្ទុងដូង

☞ ក្រោយទិច ៥ថ្ងៃ ដង្កូវខ្ទុងបញ្ឈប់ស៊ីចំណី

☞ ក្រោយទិច ៧ថ្ងៃ ដង្កូវខ្ទុងដូងងាប់និងចាប់ផ្ដើមប្រែពណ៌

☞ ក្រោយទិច ១០ ថ្ងៃ ដង្កូវខ្ទុង មានប្រែពណ៌ត្នោត

☞ ក្រោយទិច ១៥ ថ្ងៃ ដង្កូវខ្ទុង មានប្រែពណ៌ត្នោតក្រម៉ៅ អាចយកទៅរំដោះបាន

☞ ក្រោយទិច ១៧ទៅ១៩ ថ្ងៃ ឱម៉ាល់អាសេកូដញាស់ចេញពីជំរកខ្មោចដង្កូវ( ម៉ាមី)

☞ ដង្កូវប្រែពណ៌ ១( ១ម៉ាមី) អាចញាស់បានឱម៉ាល់ពី **៣០ ទៅ ៦០** ឱម៉ាល់